សីលធម៌ និង អសីលធម៌ ?

នៅពេល មាន មរណភាព អ្នកដឹកនាំ នៅ ស្រុកខ្មែរ ម្តងៗ ខ្មែរ យើង ភាគច្រើន ដែល មាន ពិភល ក្នុង ចិត្ត ថា ខ្លួន ជា អ្នក រងគ្រោះ ត្រប់ រូបភាព ពី សំណាក់ អ្នកដឹកនាំ តែង ទុក មរណ ភាព នោះ ជា សោមគ្រោះ (événements heureux) ព្រោះ ជា អ្នកខ្សោយ គ្មាន អ្វីទៀត អាច ប្រឆាំងនឹង អំពើ អយុត្តិធម៌ ហិង្សា សែនទ្វី ដែល ខ្លួន បាន ទទួល ពី សំណាក់ អ្នកដឹងនាំ ទាំងនោះ ក្រៅ ពី ការសំដែង ទឹកចិត្ត សោមនស្ស យ៉ាងដូច្នេះ ឯង។ សួរ ថា តើ វា ជា បដិក្ខិត[1] (réflexe) ឬ វា ជា ការជញ្ជឹងគិត ដែល អាច ទុក វា បាន ជា អកប្បកិរិយា អសីលធម៌ ?

សិក្ខាបទ របស់ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទូមាន អោយ មនុស្ស លោក ទទួលស្គាល់ នូវ « កម្មផល » នៃ អំពើ របស់ខ្លួន ដែល កើតឡើង ក្រោយពេល ដែល អំពើ ត្រូវបាន ប្រព្រឹត្ត ហើយ មរណភាព នៃ មនុស្សលោក ជា អនិច្ចំ ទុក្ខំ អនត្តា (សេចក្ដី មិនទៀង) នៃ ជីវិត របស់ខ្លួន។ ដូច្នេះ អ្នក ធ្វើបុណ្យ បាន ទទួល កុសល បុណ្យ, អ្នកធ្វើបាប បានទទួល បាប ជា អកុសល។ អាស្រ័យហេតុនេះ បើ អ្នកស្លាប់ ជា ពុទ្ធបរិស័ទ ព្រលឹង ខ្ទោច នោះ តែងតែ អនុចរ តាម (ដើរតាម) ធម៌ព្រះ គឺ « កម្មផល »

[1] បដិក្ខិត; ដែលធ្វើដោយតតគិត។

សីលធម៌ និង អសីលធម៌ ?

តែ នៅ ក្នុង សីលធម៌ នៃ មនុស្សលោក វិញ ដែល ខ្ញុំរយើង តែង ថ្លែង បែងចែក អ្នកស្លាប់ ក្នុង ធម៌ ពី អ្នកស្លាប់ ក្នុង បាប, គេ អាចសួរ ថា តើ សុភវិនិច្ឆ័យ នេះ វា ជា កិច្ចការ របស់ អ្នកណា ? គឺ របស់ មនុស្សលោក ដូច្នេះ វា ស្ថិត នៅ ក្នុង រង្វង់ (domaine) នៃ សេរីភាព របស់ បុគ្គលម្នាក់ៗ។ អ្នក មាន ធម៌ ព្រះ ក្នុង ចិត្ត ច្រើន តែងតែ ប្រគល់ ការវិនិច្ឆ័យ នោះ ដល់ ច្បាប់ « កម្មផល » ដូច្នេះ ទោះបីខ្លួន បានទទួល រងគ្រោះ ពី សំណាក់ មនុស្ស ជា ខ្មោច នោះ គេ អាច មាន ករុណ្ណភាព (pardon) ក្នុង ទឹកចិត្ត ដ៏ ទូលាយ របស់គេ ជា ពុទ្ធបរិស័ទ។ តែ មនុស្ស សាមញ្ញ តែងតែ មាន ការឈឺចាប់ ក្នុង ចិត្ត មិនអាច លុបបាន នូវ អំពើ វិសមធម៌ ដែល ខ្លួនបាន ទទួលរង ពី សំណាក់ មនុស្ស ជា ខ្មោច នោះ ដូច្នេះ វា តែងតែ មាន ប្រតិកម្ម ជា កំហឹង តាម អារម្មណ៍ ក្តី តាម សំដី ក្តី ជា អ្នករងគ្រោះ។ កំហឹង នោះ ជួន វា មាន កំរិត ខ្ពស់, មធ្យម ឬ តិច ទៅតាម ស មាមាត្រ នៃ អំពើ អយុត្តិធម៌ ដែល ខ្លួន បាន ទទួល។ នៅ ក្នុង ប្រទេស មាន នីតិរដ្ឋ វា មាន ច្បាប់ សំរាប់ រំងាប់ កំហឹង; តែ បើ គ្មាន ច្បាប់ សំរាប់ ការពារ យុត្តិធម៌វិញ ដូច្នេះ ការសំដែង ទឹក ចិត្ត សោមនស្ស ជា កំហឹង របស់ ជនរងគ្រោះ វា មិនអាច ទុក ជា អកប្បកិរិយា អសីលធម៌ បាន នោះឡើយ ព្រោះ កំហឹង នោះ ជា ពំនឹង ទោល នូវ អ្វីអាចមានបាន (seul recours possible) នៃ ជនរងគ្រោះ ដូចយ៉ាង ខ្ញុំ ជា ជនរងគ្រោះ ពី នយោបាយ នៃ របបផ្តាច់ការ សព្វថ្ងៃ មាន សំណើច ជា កំហឹង ព្រោះ ខ្លួន

សីលធម៌ និង អសីលធម៌ ?

មាន ប្រាក់ខែ ក្រោម ៧៥ ដុល្លារ ខំ ត្រដរ រស់ រៀងរាល់ថ្ងៃ សំរាប់ ចិញ្ចឹម គ្រួសារ ហើយ ពេល ឮ ថា រដ្ឋាភិបាល បំរុង ចំណាយ ថវិកាជាតិ ចំនួន ៧,៥ សែន ដុល្លារ សំរាប់ ធ្វើ បុណ្យសព លោក សុខ អាន វា នាំ អោយ សើច ក្នុង ទុក្ខ ដែល ជា កំហឹង ត្រឹមត្រូវ ពុំ អាច ទុកវា ជា អកប្បកិរិយា អសីលធម៌ នោះឡើយ។ ហើយ បើ មាន គេ លើក ករណី មិនប្រក្រតី នោះ មក និយាយ ជា ពិសេស បើ ជន នោះ ជា តំណាងរាស្ត្រ វា ជា ករណីយកិច្ច របស់ គាត់ (ករណី លោក លឹម គឹម យា តំណាងរាស្ត្រ ខេត្តកំពង់ធំ)។ អសីលធម៌ គឺ នៅត្រង់ សីហា ដែល ជា ជន អនាមិក តែងតែ លួចថត សង្ហថា ជា ឯកជន តាម ទូរស័ព្ទ មក ផ្សាយ ជា សាធារណ: ហើយ ក្នុង ករណី លោក លឹម គឹម យា ថែមទាំង គំរាម ដល់ សុវត្ថិភាព របស់គាត់ ទៅទៀត។ ហើយ ឥឡូវ ថា មាន ក្រុម និស្សិត សាកលមហាវិទ្យាល័យ ផ្ទះកំហឹងនឹងគាត់ ព្រោះ ចោទ គាត់ ថា ប្រើ សម្ដី ប្រមាថ ខ្ជោច លោក សុខ អាន ហើយ ក្រុម នោះ មាន គោលបំណង នាំគ្នា ទៅ រាយ គាត់ ដល់ ផ្ទះគាត់។ តើ ជន អនាមិក សីហា ទុក ក្រោធ បែប នេះ ជា កលហពិរោធ ប្រកប ដោយ សីលធម៌ ?

បើ ជន អនាមិក សីហា គាត់ ទុក កំហឹង ក្រុម និស្សិត នឹង លោក លឹម គឹម យា ថា ជា សីលធម៌ គឺ ច្បាស់ ជា ឋានៈវិទ្យា (niveau d'éducation) របស់គាត់ វា នាំចោទ ជា បញ្ហា នៃ បញ្ហា ទូរ ការបែងចែក ទូរ អត្ថន័យ នៃ ពាក្យ សីលធម៌ និង អសីលធម៌ នៅ ស្រុកខ្មែរ សព្វថ្ងៃ ជា ពុំខាន។